ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំចក្រភពអង់គ្លេស

# សេចក្តីជូនដំណឹង
# ស្តីពី
# ការកែសម្រួលកាលបរិច្ឆេទរៀបចំ
# ទិវាវប្បធម៌ជាតិ ៣ មីនា លើកទី២៥ ឆ្នាំ២០២៣

ស្ថានឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំចក្រភពអង់គ្លេស មានកិត្តិយសសូមជម្រាបជូនថា យោងសេចក្តីជូនដំណឹងរបស់ស្ថានទូត កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៣ និងតាមសំណូមពររបស់បងប្អូនប្រជាពលរដ្ឋ និងសិស្ស-និស្សិតខ្មែរ ស្ថានទូតនឹងធ្វើការផ្លាស់ប្តូរកាលបរិច្ឆេទរៀបចំ **ទិវាវប្បធម៌ជាតិ ៣ មីនា លើកទី២៥ ឆ្នាំ២០២៣** ក្រោមប្រធានបទ **«យុវជនដើម្បីវប្បធម៌ជាតិ»** ដែលគ្រោងនឹងប្រព្រឹត្តទៅនៅថ្ងៃពុធ ទី១៥ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ១១ ព្រឹក ទៅ**ថ្ងៃអាទិត្យ ទី១២ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ១១ ព្រឹក** វិញ នៅស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំចក្រភពអង់គ្លេសដែលមានអាសយដ្ឋាន៖ 64 Brondesbury Park, Willesden Green, NW6 7AT, London, United Kingdom។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមបងប្អូនប្រជាពលរដ្ឋខ្មែរ និងសិស្ស-និស្សិតដែលកំពុងរស់នៅ និងកំពុងសិក្សានៅចក្រភពអង់គ្លេស មេត្តាជ្រាបជាព័ត៌មាន និងចូលរួមកម្មវិធីខាងលើនេះ។ ចំពោះបងប្អូនប្រជាពលរដ្ឋខ្មែរ និងសិស្ស-និស្សិត ដែលមានបំណងចូលរួមកម្មវិធីខាងលើនេះ សូមចុះឈ្មោះតាមរយៈ Link៖ https://forms.office.com/r/d7i5U5p79s **ឱ្យបានមុនថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣។**៕

សូមអរគុណ!

ថ្ងៃព្រហស្បតិ៍ ៤ រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ទីក្រុងឡុងដ៍, ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២៣

សូម Scan QR Code
ដើម្បីចុះឈ្មោះ

64 Brondesbury Park, Willesden Green, London NW6 7AT, Tel: +44 20 8451 7850, Fax: +44 20 8451 7594
Email: cambodianembassy@btconnect.com Website: www.cambodianembassy.org.uk